**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់**

លេខ:...៣១០ សរាស

លិខិតចូល
ថ្ងៃទី 23 ខែ មិថុនា ឆ្នាំ 2006

# សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតគណៈកម្មការខេត្ត ក្រុង ទទួលបន្ទុកការងារកំណត់ព្រំប្រទល់រដ្ឋបាលឃុំ សង្កាត់ និងគណៈកម្មាធិការស្រុក ខណ្ឌ ទទួលបន្ទុកការងារកំណត់ព្រំប្រទល់រដ្ឋបាលឃុំ សង្កាត់

---

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**
**និងជាប្រធានអនុគណៈកម្មការ នគរូបនីយកម្ម និងព្រំប្រទល់ឃុំ សង្កាត់**
**នៃគណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/ រកត /០៧០៤/ ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការ តែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើ ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី ២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/៥០១/១៧៥ ចុះថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីការបង្កើតគណៈកម្មាធិការជាតិគាំទ្រ ឃុំ-សង្កាត់
- យោងសេចក្តីសំរេច ០១៤/០១ សរ /គឃស ចុះថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០០១ របស់គណៈកម្មាធិការជាតិគាំទ្រ ឃុំ-សង្កាត់ ស្តីពីការបង្កើតអនុគណៈកម្មការនានាចំណុះគណៈកម្មការជាតិគាំទ្រ ឃុំ សង្កាត់
- បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្ត ទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- យោងលិខិតលេខ ៤៨៥ សជណ ចុះថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០០៦ របស់ក្រសួងមហាផ្ទៃ
- តាមការចាំបាច់របស់អនុគណៈកម្មការ នគរូបនីយកម្ម និងព្រំប្រទល់ឃុំ សង្កាត់

## ស ម្រេ ច

**ប្រការ ១** : ត្រូវបានបង្កើតគណៈកម្មការខេត្ត ក្រុង ទទួលបន្ទុកការងារព្រំប្រទល់រដ្ឋបាលឃុំ សង្កាត់ ដែលមានសមាសភាពដូចខាងក្រោម :

- អភិបាល ឬអភិបាលរងខេត្ត ក្រុង ប្រធាន
- ប្រធានមន្ទីរ រៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្ត ក្រុង សមាជិកអចិន្ត្រៃយ៍

អាសយដ្ឋាន : លេខ ៧៧១-៧៧៣ មហាវិថី ព្រះមុនីវង្ស សង្កាត់ បឹងត្របែក ខណ្ឌ ចំការមន ក្រុងភ្នំពេញ
Tel : (855) 023 215 659 - 215 660 , Fax : (855) 023 215 277, e-mail : im. c . lim. @ Camnet. Com. kh

- ប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្ត ក្រុង សមាជិក
- មេបញ្ជាការកងរាជអាវុធហត្ថ ខេត្ត ក្រុង សមាជិក
- មេបញ្ជាការតំបន់ប្រតិបត្តិការសឹករង ខេត្ត ក្រុង សមាជិក
- ស្នងការនគរបាល ខេត្ត ក្រុង សមាជិក
- អភិបាលស្រុក ខណ្ឌ សមាជិក
- ប្រធានអង្គភាពរដ្ឋបាលមូលដ្ឋាន ខេត្ត ក្រុង សមាជិក
- មន្ត្រីជំនាញសាលា ខេត្ត ក្រុង ទាំង២រូបដែលបានទទួលការបណ្តុះបណ្តាលបច្ចេកទេស សមាជិក

**ប្រការ២:** គណៈកម្មការខេត្ត ក្រុង ទទួលបន្ទុកការងារព្រំប្រទល់រដ្ឋបាលឃុំ សង្កាត់ មានភារកិច្ច :

- ដឹកនាំការងារកំណត់ព្រំប្រទល់រដ្ឋបាលឃុំ សង្កាត់នៅក្នុងខេត្ត ក្រុងក្នុងសមត្ថកិច្ច
- ដឹកនាំ និងផ្តួចផ្តើមរាល់កិច្ចប្រជុំដែលពាក់ព័ន្ធនឹងការងារកំណត់ព្រំប្រទល់រដ្ឋបាលឃុំ សង្កាត់ ស្ថិតក្នុងខេត្ត ក្រុង ពីរផ្សេងគ្នា និង ស្រុក ខណ្ឌ ពីរផ្សេងគ្នាដែលមានព្រំប្រទល់ជាប់គ្នា
- ដឹកនាំសម្របសម្រួលដើម្បីស្វែងរកការឯកភាពគ្នាលើព្រំប្រទល់រដ្ឋបាលឃុំ សង្កាត់ក្នុងករណីដែលបច្ចុប្បន្នមិនទាន់មានការឯកភាព
- សមាជិកអចិន្ត្រៃយ៍ និងមន្ត្រីជំនាញ២រូបដែលបានទទួលការបណ្តុះបណ្តាលបច្ចេកទេសហើយ ជាអ្នកអនុវត្តការងារគូសផែនទី និងធ្វើកំណត់ហេតុរាល់កិច្ចប្រជុំ ដែលពាក់ព័ន្ធនឹងការងារកំណត់ព្រំប្រទល់ឃុំ សង្កាត់ ដើម្បីដាក់ជូនប្រធានគណៈកម្មការខេត្ត ក្រុង ទទួល បន្ទុកព្រំប្រទល់រដ្ឋបាលឃុំ សង្កាត់ ពិនិត្យសំរេច
- ធ្វើរបាយការណ៍ស្តីពីលទ្ធផលការងារ និងលើកសំណើផ្សេងៗដោយភ្ជាប់ជាមួយនូវឯកសារពាក់ព័ន្ធ ជូនអនុគណៈកម្មការនគរូបនីយកម្ម និងព្រំប្រទល់រដ្ឋបាលឃុំ សង្កាត់ ពិនិត្យ មុននឹងដាក់ជូនគណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ និងក្រសួងមហាផ្ទៃពិនិត្យសំរេច
- សមាជិកទាំងអស់ត្រូវចូលរួមប្រជុំតាមការកោះអញ្ជើញរបស់ប្រធាន

**ប្រការ៣:** ត្រូវបានបង្កើតគណៈកម្មការស្រុក ខណ្ឌ ទទួលបន្ទុកការងារព្រំប្រទល់រដ្ឋបាលឃុំ សង្កាត់ ដែលមានសមាសភាពដូចខាងក្រោម :

- អភិបាល ឬអភិបាលរង ស្រុក ខណ្ឌ ប្រធាន
- ប្រធានការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលស្រុក ខណ្ឌ សមាជិកអចិន្ត្រៃយ៍
- មេបញ្ជាការកងរាជអាវុធហត្ថ ស្រុក ខណ្ឌ សមាជិក
- មេបញ្ជាការផ្នែកសឹករងស្រុក ស្រុក ខណ្ឌ សមាជិក
- អធិការនគរបាល ស្រុក ខណ្ឌ សមាជិក
- ប្រធានក្រុមប្រឹក្សា ឃុំ សង្កាត់ សមាជិក

**ប្រការ៤:** គណៈកម្មការស្រុក ខណ្ឌ ទទួលបន្ទុកការងារព្រំប្រទល់រដ្ឋបាលឃុំ សង្កាត់ មានភារកិច្ច :

- ដឹកនាំការងារកំណត់ព្រំប្រទល់រដ្ឋបាលឃុំ សង្កាត់នៅក្នុងស្រុក ខណ្ឌក្នុងសមត្ថកិច្ច តាមការណែនាំរបស់គណៈកម្មការ ខេត្ត ក្រុងទទួលបន្ទុកព្រំប្រទល់រដ្ឋបាលឃុំ សង្កាត់

- ដឹកនាំ និងផ្តួចផ្តើមរាល់កិច្ចប្រជុំពាក់ព័ន្ធនឹងការងារកំណត់ព្រំប្រទល់រដ្ឋបាលឃុំ សង្កាត់ ស្ថិតក្នុង ស្រុក ខណ្ឌ ពីរផ្សេងគ្នា ដែលមានព្រំប្រទល់ជាប់គ្នា
- ដឹកនាំសម្របសម្រួលដើម្បីស្វែងរកការឯកភាពគ្នាលើព្រំប្រទល់រដ្ឋបាលឃុំ សង្កាត់ក្នុងករណីដែលបច្ចុប្បន្នមិនទាន់មានការឯកភាព
- សមាជិកអចិន្ត្រៃយ៍មានភារៈកិច្ចពិគ្រោះយោបល់ផ្នែកបច្ចេកទេស ជាមួយមន្ត្រីជំនាញទាំងពីររូបនៅក្នុងគណៈកម្មការខេត្ត ក្រុង គ្រប់កិច្ចការពាក់ព័ន្ធទាំងអស់
- ធ្វើរបាយការណ៍ពីលទ្ធផលការងារ និងសំណើផ្សេងៗដោយភ្ជាប់ជូននូវឯកសារពាក់ព័ន្ធ ជូនគណៈកម្មការខេត្ត ក្រុង ទទួលបន្ទុកកំណត់ព្រំប្រទល់រដ្ឋបាលឃុំ សង្កាត់ ពិនិត្យសំរេច
- សមាជិកគណកម្មការត្រូវចូលរួមប្រជុំតាមការកោះអញ្ជើញរបស់ប្រធាន

**ប្រការ៥:** គណៈកម្មការខេត្ត ក្រុង ទទួលបន្ទុកការងារព្រំប្រទល់រដ្ឋបាលឃុំ សង្កាត់ និងគណៈកម្មការស្រុក ខណ្ឌ ទទួលបន្ទុកការងារព្រំប្រទល់រដ្ឋបាលឃុំ សង្កាត់ ត្រូវបំពេញការងាររបស់ខ្លួនដោយសហការជិតស្និទ្ធជាមួយក្រុមការងារបច្ចេកទេស អន្តរក្រសួងកំណត់ព្រំប្រទល់រដ្ឋបាលឃុំ សង្កាត់ ។

**ប្រការ៦:** នាយកខុទ្ទកាល័យ អគ្គនាយកគ្រប់អគ្គនាយកដ្ឋាន សមាសភាពគណៈកម្មការខេត្ត ក្រុង ទទួលបន្ទុកការងារ ព្រំប្រទល់ រដ្ឋបាលឃុំ សង្កាត់ សមាសភាពគណៈកម្មការស្រុក ខណ្ឌ ទទួលបន្ទុកការងារព្រំប្រទល់រដ្ឋបាលឃុំ សង្កាត់ ដូចមាន ចែងក្នុងប្រការ១ និងប្រការ៣ ត្រូវអនុវត្តសេចក្តីសំរេចនេះអោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។ ៚

ភ្នំពេញ,ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០០៦

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

និងជាប្រធានអនុគណៈកម្មការ នគរូបនីយកម្ម និងព្រំប្រទល់ឃុំ សង្កាត់

នៃគណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់

អ៊ឹម ឈុនលឹម

**កន្លែងទទួល**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងការពារជាតិ
- ក្រសួងកសិកម្ម
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ស ខេង
- គ្រប់សាលាខេត្ត ក្រុង
- ដូចប្រការ ៦
- ឯកសារ-កាលប្បវត្តិ